

# រក្សាទុកក្នុងបេះដូង

ខាំប៉ុន អក្សរវិល័យ ដកស្រង់ចេញពីពាក្យបរិយាយអធិប្បាយរបស់ សុចិន្ត បរិហានវ៉នខេត្ត

បកប្រែពីភាសាថៃ មកជាខេមរភាសា ដោយសមាជិក ម.ស.ផ ២ រូប

មូលនិធិសិក្សានិងផ្សព្វផ្សាយព្រះពុទ្ធសាសនា

# ហាងយេ ដិដេតព្វយុត្តកាំ

## រក្សាទុកក្នុងបេះដូង

# រក្សាទុកក្នុងបេះដូង

## ខាំប៊ុន អក្សរវិល័យ ដកស្រង់ចេញពីពាក្យបរិយាយអធិប្បាយរបស់ សុចិន្ត បរិហានរនខេត្ត

## មូលនិធិសិក្សានិងផ្សព្វផ្សាយព្រះពុទ្ធសាសនា

១. បញ្ញា ការយល់ត្រូវ ឃើញត្រូវ

នាំទៅនូវកិច្ចទាំងពួងដែលចម្រើន ដែលជាកុសល ដែលត្រឹមត្រូវ

មិនមែនមានយើងបង្គាប់បញ្ញាខ្លួនឯងឱ្យជាមនុស្សល្អបានទេ

ប៉ុន្តែការយល់ព្រះធម៌វិញទេដែលសន្សឹមៗ កាត់នូវកិលេស(ដែលជា)សេចក្ដីមិនល្អ

និងការមិនដឹង ។

២. យ៉ាងណាក៏ត្រូវតែស្លាប់ ក៏ត្រូវធ្វើសេចក្ដីល្អអោយច្រើនបំផុត មិនល្អជាងឬ ?

យល់ព្រះធម៌អោយច្រើនបំផុត មិនល្អជាងឬ ?

(នោះ)នឹងបានជាប់ទៅ(ជាមួយ)បាន ។ នឹងបោះបង់ឱកាសសន្សំសេចក្ដីល្អ

និងស្ដាប់ព្រះធម៌បានយ៉ាងដូចម្ដេច ?

៣. ការដែលកុសលនឹងចម្រើនឡើងបាននោះ ត្រូវតែជាអ្នកដែលឃើញគុណពិត ៗ

របស់កុសល ដែលនឹងប្រព្រឹត្តទៅដើម្បីការដុសខាត់អកុសល

ទើបមិនព្រងើយកណ្ដើយឱកាសដែលនឹងបានសន្សំសេចក្ដីល្អក្នុងជីវិតប្រចាំថ្ងៃ

មិនថានឹងជាឱកាសរបស់សេចក្ដីល្អប្រភេទណាក៏បាន ។

៤. មិនគួរមានការគិតមិនល្អជាមួយនរណាៗឡើយ

ព្រោះហេតុថា ជាទោសរបស់ខ្លួនឯង

ហើយទោសនេះប្រសិនបើជាអកុសលកម្ម ក៏នឹងធ្វើអោយកើតក្នុងអបាយភូមិបាន ។

៥. លះវត្ថុរបស់របរឱ្យទាន

លះសេចក្តីក្រោធភាពចង្អៀតចង្អល់ចិត្តនឹងអ្នកដទៃ

អត់ធន់អោយខ្លាំងបំផុតដែលនឹងបំពេញសេចក្តីល្អគ្រប់យ៉ាង

នេះឯងជាការដែលបន្ថែមនូវសេចក្តីល្អជារឿយៗ ។

៦. ត្រឹមតែពាក្យថា ធម្មៈជាធម្មៈ រក្សាទុកក្នុងបេះដូងឬទេ ?

សមគួរដែលនឹងរក្សាទុកយ៉ាងគង់វង្សបំផុត មិនមែនយើង មិនមានយើង

មានតែធម្មៈ ទាំងអស់ដែលមានជាធម្មៈ

នេះឯងជាពាក្យដែលគួររក្សាទុកក្នុងបេះដូង

ព្រោះហេតុថា ជាការពិតយ៉ាងនេះជារៀងរហូត ។

៧. យើងលាពីលោកមុនមក ដោយមិនដឹងសោះថា

យើងនឹងជាយ៉ាងនេះក្នុងលោកនេះ ដូច្នេះ

ដល់ពេលដែលនឹងលាពីលោកនេះទៅ ក៏ធម្មតា

ព្រោះដូច្នោះ ក៏សន្សំសេចក្តីល្អ សន្សំបញ្ញាការយល់ឃើញត្រូវ

ព្រោះហេតុថា ប្រសិនបើមិនមានការយល់ធម្ម

សេចក្តីល្អក៏សែនលំបាកនឹងច្រើនឡើងចម្រើនឡើងបាន ។

៨. រឿងណាដែលនឹងមិនជាប្រយោជន៍ដល់ព្រះរតនត្រ័យ

នឹងធ្វើឱ្យកើតការយល់ខុសឃើញខុស

ក៏ត្រូវតែជាបុគ្គលត្រង់ដែលនឹងមិនគាំទ្រនូវរឿងនោះ ។

៩. គេក៏មានអកុសល យើងក៏មានអកុសល ប្រសិនបើនរណាកំពុងនៅខឹងនរណា

ឬមិនចូលចិត្តនរណាក៏ដោយ សូមអោយសាកគិតថា

យើងនឹងឃើញគេជាលើកចុងក្រោយ ហើយក៏មិនឃើញគ្នាទៀតឡើយ

ព្រោះហេតុដូច្នោះ នឹងធ្វើអ្វី នៅពេលដែលឃើញគ្នាជាលើកចុងក្រោយ

នឹងធ្វើល្អ ឬនឹងធ្វើអាក្រក់ដាក់គ្នា ?

១០. ធ្វើនូវរឿងដែលត្រឹមត្រូវ ដោយបំណងល្អ នរណានឹងស្រឡាញ់ នរណានឹងស្អប់

នឹងមិនពេញចិត្តយ៉ាងណា ក៏ហាមមិនបាន ។

១១. ប្រសិនបើមិនមែនជាការផ្តោត(តែ)លើការលះនូវកិលេស

មិនចាំបាច់ឡើយដែលនឹងត្រូវទៅបួសជាភេទបព្វជិត

ព្រោះជាគ្រហស្ថក៏ស្តាប់ធម៌បាន យល់ធម៌បាន

កាត់បង់នូវកិលេសបានដែរ ។

១២. មិនសិក្សាព្រះពុទ្ធសាសនា

នឹងរក្សាព្រះពុទ្ធសាសនាទុកបានយ៉ាងដូចម្តេច ?

មានតែដឹកនាំគ្នាធ្វើក្នុងរឿងដែលខុស ប្រព្រឹត្តខុស

នេះជាការបំផ្លាញព្រះពុទ្ធសាសនា ។

១៣. ប្រសិនបើយើងធ្វើនូវអំពើល្អ ខ្លាចអ្វី ?

អ្នកដទៃនឹងតិះដៀល រឿងរបស់គេ

អ្នកដទៃមិនចូលចិត្ត ក៏រឿងរបស់គេ ។

អ្នកដទៃនឹងគិតយ៉ាងណា ក៏ជារឿងរបស់គេ

តែអ្វីដែលយើងធ្វើជាប្រយោជន៍ឬទេ?

ប្រសិនបើជាប្រយោជន៍ គួរធ្វើទេ ?

ប្រសិនបើជារឿងដែលល្អ ជាប្រយោជន៍ ក៏គួរធ្វើ ។

១៤. ទោះបីជាអ្នកដទៃខឹង

ក៏មិនគួរនឹងយកឈ្នះសេចក្តីក្រោធរបស់អ្នកដទៃ

ដោយការក្រោធខឹងតប(ឡើយ)។ ប៉ុន្តែនៅពេលដែលអ្នកដទៃខឹងក្រោធ

យើងឈ្នះកិលេសរបស់ខ្លួនឯងដោយមិនខឹងតបអ្នកដែលខឹង

នោះជាប្រយោជន៍ដ៏ធំក្រៃលែង ។

១៥. ជីវិតខ្លីណាស់ ជាតិនេះសន្សំអ្វីទុក

ប្រសិនបើជាការយល់ដែលត្រឹមត្រូវ ក៏នឹងមានឱកាសបានឮ បានស្តាប់តទៀត

ពិចារណាតទៀត ឃើញត្រូវតទៅទៀត ។

ប៉ុន្តែបើយល់ខុស ក៏ទៅផ្លូវខុសរហូតទៅក្នុងសង្សារវដ្ត

សូម្បីបានឮ បានស្តាប់ពាក្យដែលត្រឹមត្រូវ ក៏(យល់)ឃើញខុសបាន ។

១៦. រឿងដែលគួរខ្លាច មិនគួរធ្វើ គឺ អកុសល។

១៧. ជីវិតខាងមុខវែងឆ្ងាយ ជាតិនេះខ្លីណាស់

ព្រោះដូច្នោះ ជាតិមុខនឹងទៅជាអ្វី

ក៏ត្រូវមកពីរឿងដែលកំពុងប្រព្រឹត្តទៅ ក្នុងខណៈនេះ ក្នុងជាតិនេះ ។

១៨. បំណងល្អឱ្យគេយល់ធម៌ ទោះគេជេរ ទោះគេនឹងថា

ប៉ុន្តែនៅតែមិនអាចធ្វើឱ្យបំណងល្អ

ដែលនឹងឱ្យគេបានយល់ការពិត ត្រូវបាត់បង់ទៅ(ឡើយ) ។

១៩. ប្រទេសជាតិ ឬពិភពលោក មានបញ្ហា

ព្រោះហេតុថា មិនបានដឹងការពិត

ហើយនៅពេលដែលមិនបានដឹងការពិត នឹងដោះស្រាយបញ្ហាបានយ៉ាងដូចម្ដេច ?

២០. ការប្រព្រឹត្តណាៗក៏ដោយរបស់អ្នកដែលមិនយល់ព្រះធម្មវិន័យ

ប៉ុន្តែគិតថាខ្លួនឯងជាពុទ្ធសាសនិកជន

ក៏បំផ្លាញពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ។

២១. អ្វីដែលមូលនិធិសិក្សានិងផ្សព្វផ្សាយពុទ្ធសាសនាធ្វើ

ក៏(ប្រកប)ដោយភាពជាមិត្តដែលល្អ ពោលរឿងដែលជាប្រយោជន៍

មិនជាទោសឡើយ ទោះបីជារឿងព្រះសូត្រ ព្រះវិន័យ

ឬព្រះអភិធម្ម ព្រមអោយអ្នករាល់គ្នាបានសន្ទនាសាកសួរ

រួមគ្នាពិចារណា រហូតដល់ជាការយល់ដែលត្រឹមត្រូវ

នេះគឺជាការសិក្សាធម៌ដែលមិនប្រមាទ ពិតៗ ។

២២. មានភាពរឹងមាំគង់វង្ស(ច្បាស់លាស់ប្រាកដប្រជា)ទេ

ដែលនឹងយល់នូវអ្វីដែលកំពុងមានក្នុងខណៈនេះតាមសេចក្ដីពិត ?

២៣. ពុទ្ធបរិស័ទត្រូវគោរពដ៏ក្រៃលែងនូវព្រះបញ្ញាគុណ

ព្រះបរិសុទ្ធិគុណ និងព្រះមហាករុណាគុណ

របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់សម្ដែងព្រះធម៌ ៤៥ វស្សា

ល្អិត(ល្អន់)ជ្រាលជ្រៅយ៉ាងក្រៃលែង ដោយប្រការទាំងពួង

ដើម្បីអ្វី? ដើម្បីសត្វលោកនឹងមិនយល់ខុស ។

២៤. មានឱកាសដែលនឹងស្ដាប់ព្រះធម៌ ក៏ស្ដាប់

សន្សំជាឧបនិស្ស័យក្នុងការស្តាប់ព្រះធម៌តទៅ ។

២៥ ជាតិមុខនឹងកើតជាអ្វីមិនមាននរណាអាចដែលនឹងដឹងបានឡើយ

ជាតិមុនមកពីណា ក៏មិនដឹង ជាតិតទៅទៀតនឹងទៅណា ក៏មិនដឹង

ប៉ុន្តែជាបុគ្គលនេះក្នុងជាតិនេះ ការ(ដែល)នឹងមានជីវិតខ្លី ឬ យឺនយូរ

ច្រើនតិចប៉ុណ្ណា ក៏មិនមាននរណាប្រាប់បានឡើយ

ព្រោះដូច្នោះ ជាមនុស្សក្នុងជាតិនេះដែលល្អជាទីបំផុត ល្អទេ ?

ឬជាមនុស្សអាក្រក់ ពុករលួយគ្រប់យ៉ាង ទុច្ចរិត

យ៉ាងនោះល្អទេ? មិនល្អ(ទេ) ។

២៦. មធ្យោបាយដែលនឹងធ្វើឱ្យមនុស្សជាអ្នកគ្រប់គ្រងប្រទេស(បាន)ល្អ

គឺ ឱ្យគេបានមាននូវការយល់ត្រូវ ឃើញត្រូវ

ព្រោះការយល់ត្រូវឃើញត្រូវ

នេះឯងនឹងនាំទៅនូវកិច្ចដែលល្អច្រើនឡើងៗ ។

២៧. ព្រះពុទ្ធសាសនាបង្រៀនមនុស្សឱ្យយល់នូវការពិតដល់ទៅបំផុត

អ្វីណា(ដែល)ត្រូវក៏ត្រូវ អ្វីដែលល្អក៏ល្អ អ្វីដែលអាក្រក់ក៏អាក្រក់ មិនច្រឡូកច្រឡំគ្នា(ឡើយ) ។

ព្រោះហេតុនោះ ប្រសិនបើមានការយល់នូវទោសរបស់សេចក្តីមិនល្អ

មានឬ មនុស្សដឹងការពិត ហើយនឹងធ្វើអាក្រក់ ?

២៨. ការយល់ត្រូវ ការឃើញត្រូវ គឺបញ្ញា

នាំទៅនូវកិច្ចទាំងពួងដ៏ល្អស្អាត ដែលជាកុសល ។

អកុសល ការមិនដឹង នឹងនាំទៅរកសេចក្តីល្អមិនបានឡើយ

ខ្លួនឯងក៏មិនល្អ ហើយនឹងនាំទៅរកសេចក្តីល្អបានយ៉ាងដូចម្តេច ?

២៩. ប្រមាទមិនបានឡើយ

ខណៈណាក៏ដោយ ឱ្យតែជាឱកាសកុសលចិត្តនឹងកើត

ប្រសិនបើបោះបង់ចោលឱកាសនោះ រំលងនូវឱកាសនោះ

ឱកាសរបស់កុសលក៏អស់ទៅ មួយខណៈៗ ច្រើនឬទេ?

ព្រោះដូច្នេះ ការស្តាប់ព្រះធម៌ ដើម្បីឱ្យស្គាល់ខ្លួនឯង

តាមសេចក្តីពិត ដើម្បីនឹងបានជាមនុស្សដែលគង់វង្ស(ប្រាកដប្រជា)ក្នុងកុសល ។

៣០. ត្រឹមតែបញ្ញាដែលឃើញទោសរបស់អកុសល ហើយក៏ឃើញប្រយោជន៍របស់កុសល

ក៏នឹងនាំសន្សឹមៗ ទៅការដែលនឹងឃើញប្រយោជន៍របស់កុសលបន្ថែមឡើង ។

៣១. ភាពជាបុគ្គលត្រង់ ត្រូវតែត្រង់តាំងតែពីពេលនេះ ខណៈនេះ

ប្រសិនបើខណៈនេះមិនត្រង់ តទៅទៀតនឹងត្រង់ឬទេ ?

នរណានឹងដឹងថាលាពីលោកនេះទៅពេលណា? ឥឡូវនេះក៏បានដែរ

ព្រោះហេតុដូច្នោះ ប្រសិនបើនឹងត្រង់

ក៏ត្រូវត្រង់តាំងតែពីពេលនេះ ក្នុងខណៈពេលដែលស្តាប់ធម៌ ។

៣២. បញ្ញាការយល់ត្រូវ ឃើញត្រូវ

ក្លាហានដែលនឹងដឹងថាអ្វីណាត្រូវ អ្វីណាខុស

បញ្ញាក្លាហានដែលនឹងមិនធ្វើនូវរឿងដែលខុស ។

៣៣. ប្រសិនបើមិនមានឱកាសបានឮ បានស្តាប់ ពាក្យរបស់ព្រះដ៏មានព្រះភាគជាអង្គម្ចាស់

ក្នុងជាតិនេះ តៗទៅ ក៏នឹងងងឹតឈឹងដូចដើម

(ដូច)ដែលមិនធ្លាប់ដឹងការពិតរបស់អ្វីដែលកំពុងមានក្នុងខណៈនេះឡើយ ។

៣៤. បុគ្គលដែលដឹងការពិត នឹងមិនធ្វើនូវអ្វីដែលមិនជាប្រយោជន៍

នឹងមិនធ្វើអ្វីដែលជាអកុសល ប៉ុន្តែនឹងធ្វើអ្វីដែលជាប្រយោជន៍

ធ្វើនូវអ្វីដែលជាកុសលថែមឡើង ព្រោះដូច្នោះ ពិភពលោកនេះនឹងសុខឡើង

ព្រោះធម៌គឺការយល់នូវការពិត ។

៣៥. ទ្រព្យសម្បត្តិមាសប្រាក់ដែលមាន ដល់ពេលដែលលះលោកនេះទៅ យកអ្វីទៅជាមួយមិនបាន

សូម្បីតែរាងកាយដែលយើងយល់ថាជាយើង

ក៏មិនអាចនឹងជាប់ទៅតាមបានឡើយ ។

ព្រោះដូច្នោះ មិនមានអ្វីនឹងជាប់ទៅតាមខ្លួនបានឡើយ

ក្រៅតែពីកុសល និងអកុលសដែលមាននៅក្នុងចិត្ត

សន្សំនៅក្នុងចិត្តគ្រប់ខណៈដែលកើតឡើងសន្សំជាប់តទៅ ។

៣៦. គ្រប់គ្នាដែលកំពុងស្តាប់ធម៌នៅក្នុងខណៈនេះ

កំពុងតែចាប់ផ្តើមនូវផ្លូវដែលនឹងដើរតទៅទៀតវែងឆ្ងាយណាស់

ព្រោះភាពជ្រាលជ្រៅរបស់ព្រះធម៌

ប៉ុន្តែបើមិនចាប់ផ្តើមសោះឡើយ(នោះ) ក៏នឹងមិនមានថ្ងៃដល់(ឡើយ) ។

ព្រោះហេតុដូច្នោះ បើសិនមានការចាប់ផ្តើមទៅតាមដែលមានបច្ច័យ

ដែលនឹងប្រព្រឹត្តទៅនៅក្នុងមួយជីវិតៗ ក៏ជាប្រយោជន៍ដ៏ក្រៃលែង ។

៣៧. ដែលកន្ទក់កន្ទេញ ដែលក្តៅក្រហាយ ដែលខ្វល់ខ្វាយ ព្រោះតែអកុសល

សូម្បីតែការគិតរបស់មនុស្សម្នាក់ៗ នៅក្នុងជីវិតប្រចាំថ្ងៃ

ភ្លាំងភ្លាត់ទៅ ក៏ព្រោះអកុសល មិនមែនព្រោះកុសលទេ ។

៣៨. អប់រំចម្រើនកុសលគ្រប់ប្រការបន្តិចម្តងៗ

ថ្ងៃណាមួយក៏នឹងមានកម្លាំងដែលនឹងធ្វើឱ្យអកុសលទន់ខ្សោយកម្លាំងចុះបាន ។

៣៩. ទានកុសលដើម្បីអ្វី? អ្នកដែលធ្វើនូវកុសលសូម្បីតែថ្នាក់ទាន

គឺការឱ្យ ក៏ត្រូវពិចារណាថាទានកុសលនេះដើម្បីអ្វី ?

ដើម្បីត្រូវការបានបុណ្យច្រើនៗ ឬដើម្បីសង្គ្រោះ

ជួយយកអាសារបុគ្គលដទៃ ? នេះក៏ត្រូវតែពិចារណា ។

៤០. ជាតិមុខនឹងកើតជាអ្វី ឥឡូវនេះមិនដឹង

ប៉ុន្តែស្លាប់ពេលណា កើតពេលណា ក៏ដឹងពេលនោះ ។

៤១. ប្រសិនបើជាអ្វីដែលត្រឹមត្រូវ ហេតុអ្វីមិនក្លាហាននឹងធ្វើ ?

និងប្រសិនបើមិនបោះបង់អ្វីដែលខុសដោយលឿន

ក៏នឹងសន្សំនូវអ្វីដែលខុសនោះ ជាប់តាមតទៅទៀតច្រើនណាស់

ព្រោះដូច្នោះ អ្នកដែលមានការយល់ត្រឹមត្រូវ

ក៏នឹងធ្វើនូវអ្វីដែលត្រឹមត្រូវ ដោយមិនមានការញាប់ញ័រ ។

៤២. ជីវិតខ្លីណាស់ អាចនឹងរស់នៅត្រឹមតែល្ងាចនេះ ឬថ្ងៃស្អែកក៏បាន

ក៏គួរនឹងបានធ្វើនូវអ្វីដែលជាប្រយោជន៍ដ៏ល្អបំផុតដល់ខ្លួនឯង

គឺ អ្វីដែលខុសក៏បោះ(បង់)ចោល និងអ្វីដែលត្រូវក៏ប្រញាប់ធ្វើ

មានន័យថា មិនរេរា ។

៤៣. ការសន្ទនាធម៌ជាមង្គល

ព្រោះធ្វើឱ្យមានការយល់ត្រូវ

ព្រោះម្នាក់ៗ អាងផ្សេងៗគ្នា មនុស្សផ្សេងគ្នាក៏គិតផ្សេងគ្នា

ក៏ជាឱកាសដែលនឹងបានរួមគ្នាពិចារណាថាអ្វីណាត្រូវ

ក៏ទទួលអ្វីដែលត្រូវ ហើយក៏បោះបង់(ចោល)នូវអ្វីដែលខុស ។

៤៤. សេចក្តីល្អពិតៗ ហើយទោះបីជានឹងមានគេដឹង ឬមិនដឹង

នរណានឹងគិតយ៉ាងណា ក៏ផ្លាស់ប្តូរសេចក្តីល្អ ឱ្យជាយ៉ាងដទៃមិនបានឡើយ ។

៤៥. ចិត្តខណៈចុងក្រោយរបស់ជាតិនេះ

ធ្វើកិច្ចផ្លាស់ប្តូរសភាពជាបុគ្គលនេះ

នឹងត្រឡប់មកជាបុគ្គលនេះម្តងទៀតសូម្បីតែមួយខណៈចិត្តក៏មិនបានដែរ

កើតជាបុគ្គលនេះបានត្រឹមជាតិនេះ តែម្តងប៉ុណ្ណោះ ។

ប៉ុន្តែនរណាក៏បង្គាប់បញ្ជាការកើតរលត់របស់ចិត្តមិនបាន

មួយរំពេចភ្លាមដែលចិត្តខណៈនេះរលត់ ជាបច្ច័យអោយចិត្តខណៈតទៅ

កើតបន្តភ្លាម ។

៤៦. ប្រសិនបើមានបុគ្គលដែលអស់អាយុជីវិតហើយ

ហើយយើងនឹងធ្វើបុណ្យឧទ្ទិសភាគផលចំណែកបុណ្យទៅឱ្យ ក៏គឺធ្វើល្អ

ព្រោះដូច្នោះ សេចក្តីល្អដែលធ្វើទៅហើយទាំងអស់ ឧទ្ទិសភាគផលកុសលបាន ។

៤៧. វត្ត ជាកន្លែងរបស់អ្នកស្ងប់ដ៏ក្រៃលែងដែលលះនូវផ្ទះសម្បែង

កម្ចាត់បង់នូវកិលេស ស្តាប់ព្រះធម៌ សន្ទនាព្រះធម៌ អប់រំចម្រើនបញ្ញា

កម្ចាត់បង់កិលេសតាមព្រះធម៌វិន័យប៉ុណ្ណោះ គឺ វត្ត

វត្ត នឹងជាយ៉ាងដទៃមិនបានឡើយ ។

៤៨. ភិក្ខុក្នុងធម្មវិន័យ(នេះ)

ជាអ្នកយល់នូវធម៌ដើម្បីកាត់បង់នូវកិលេស

ទើបធ្វើឱ្យ កាយ វាចាស្ងប់ តាមចិត្តដែលស្ងប់ ។

៤៩. ប្រសិនបើនរណាក៏ដោយ បានយល់នូវធម៌

ក៏គិតឱ្យអ្នកដទៃបានដឹង បានយល់ផងដែរ

ទោះជានរណាៗ មិនគិតកែខៃ

ប៉ុន្តែសម្រាប់អ្នកដែលយល់ធម៌ ហើយកែខៃ

តែមួយៗទៅ ក៏គង់តែនឹងទំនុកបម្រុងព្រះពុទ្ធសាសនាទុកបាន ។

៥០. ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បញ្ញត្តថា

ព្រះភិក្ខុក្នុងធម្មវិន័យនេះ មិនទទួល និងមិនរីករាយ នូវមាសនិងប្រាក់

ហើយគ្រហស្ថយកលុយទៅឱ្យព្រះភិក្ខុ

គោរពនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ឬទេ ?

៥១. ការយល់នូវការពិតរបស់ធម៌

នឹងនាំទៅនូវកុសលធម៌ទាំងពួង មិនរារាំងឱកាសផងដែរ។

ព្រោះនរណានឹងដឹងថានឹងលាលោកនេះទៅថ្ងៃណា ?

ឥឡូវនេះក៏បាន ល្ងាចនេះក៏បាន ។

៥២. ឱកាសដែលនឹងធ្វើអំពើល្អ ពិបាករក។

ព្រោះដូច្នោះ ឱកាសដែលនឹងធ្វើអំពើល្អពេលណា

បើមិនធ្វើ ខណៈនោះក៏ជាអកុសល ក៏សន្សំអកុសលតទៅ ។

៥៣. បើគេវាយពស់ ពស់នឹងឈឺឬទេ? ហើយហេតុអ្វីទៅធ្វើឱ្យអ្នកដទៃឈឺ

ទាំងដែលខ្លួនឯងក៏ដឹងដែរថា មិនមាននរណាចូលចិត្តឈឺឡើយ ?

៥៤. មេត្តា មិនមែនទន្ទេញរឿងឈ្មោះពាក្យ(ឡើយ)

ប៉ុន្តែខណៈនោះ សភាពចិត្តដែលល្អស្អាតកើតឡើង

មានភាពជាមិត្ត មានភាពជាសម្លាញ់

មិនថាជួបនរណា ក៏មានបំណងល្អព្រមដែលនឹងធ្វើប្រយោជន៍ជួយសង្គ្រោះ ។

៥៥. ទោះបីជាបានយ៉ាងដទៃច្រើនសម្បើមមហាសាល

ក៏បាត់បង់ចោលបាត់ទៅបានគ្រប់ខណៈ

សូម្បីតែរាងកាយនេះវិនាសបាត់បង់ទៅបាន (ដោយ)ចំណែកណាមួយគ្រប់ខណៈ ។

ព្រោះដូច្នោះ អ្វីដែលសន្សំរក្សាទុក

មិនមាននរណាយកទៅបានឡើយ(នោះ)ក៏គឺ ការដែលយល់នូវព្រះធម៌ ។

៥៦. ប្រសិនបើមិនមានពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

នឹងមានអ្វីជាគ្រឿងចង្អុលបង្ហាញថា ត្រូវ ខុស យ៉ាងណា(ឡើយ) ។

៥៧. ម្នាក់ៗ ដែលពោលពាក្យពិតរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

ក៏ជាអ្នកដែលដឹងគុណរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

ទើបពោលនូវគុណរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

និងពោលពាក្យដែលព្រះអង្គត្រាស់ទុកល្អហើយ

ក៏ជាអ្វីដែលជាប្រយោជន៍ ដែលនឹងធ្វើឱ្យជនដ៏ច្រើន

បានរួចផុតពីការដែលសន្សំនូវការយល់ខុសតទៅទៀត

ដែលមិនមែនតែជាតិនេះតែមួយ(ឡើយ) ។

៥៨. ពេលដែលត្រូវស្លាប់ អាចនឹងជាថ្ងៃនេះ ឬថ្ងៃស្អែក

ឬខែក្រោយ ឬ ឆ្នាំក្រោយក៏បាន

ហេតុអ្វីមិនធ្វើនូវអំពើល្អ ហេតុអ្វីមិនចាប់ផ្ដើមស្ដាប់ធម៌អោយយល់ត្រឹមត្រូវ ?

ព្រោះជាទីពឹងតទៅទៀត ។

៥៩. ជារបស់ដែលមានប្រយោជន៍បំផុត ដែលនឹងមានការយល់ត្រូវ

ដើម្បីនឹងបានជាមនុស្សល្អ ព្រោះមានការយល់ត្រូវថាអ្វីត្រូវ

អ្វីខុស ជាមនុស្សល្អ ព្រោះយល់នូវធម៌ ។

៦០. បើសិនជាមនុស្សចាស់មិនដឹងធម៌ហើយ នឹងទៅដឹកនាំក្មេងបានយ៉ាងដូចម្តេច ?

ក្មេងក៏នឹងត្រូវតែខុស ព្រោះការដែលមិនយល់របស់មនុស្សចាស់ ។

ការពិតនោះ មនុស្សធំគួរតែមានការយល់ត្រឹមត្រូវ

ទើបនឹងអាចជួយសង្គ្រោះក្មេង ឱ្យមានការយល់ដែលត្រឹមត្រូវបាន ។

៦១. សេចក្តីស្លាប់នឹងកើតពេលណាក៏ត្រឹមតែមួយខណៈចិត្ត កើតហើយក៏រលត់

ចិត្តនោះធ្វើកិច្ចផ្លាស់ប្តូរសភាពជា(ពី)បុគ្គលនេះ

ដោយមិនសេសសល់ នឹងត្រឡប់មកជាបុគ្គលនេះមិនបានឡើយ សូម្បីតែមួយខណៈ

នឹងយកលុយជាច្រើនមហាសាល ដែលនឹងឱ្យនៅស្ថិតថេរតទៅមួយខណៈទៀត

ក៏មិនបានឡើយ ។

៦២. យល់នូវធម៌ នៅពេលមានបញ្ញាហើយ

បញ្ញាក៏នាំទៅក្នុងកិច្ចទាំងពួងដែលល្អស្អាត

អ្វីដែលត្រឹមត្រូវ ត្រូវតែត្រឹមត្រូវ មិនមែន(ជា)អ្វីដែលខុស

មិនសំខាន់ថានរណានឹងស្រឡាញ់ នរណានឹងស្អប់ឬយ៉ាងណា

តែបានធ្វើនូវអ្វីដែលត្រូវ ក៏ជាប្រយោជន៍ដែលល្អបំផុតក្នុងជីវិត ។

៦៣. វត្តជារបស់ព្រះភិក្ខុឬទេ ? មិនមែនទេ ។

ជារបស់ចៅអាវាស (ចៅអធិការ) ឬទេ ? មិនមែនទេ ។ តែវត្តជារបស់សង្ឃ

ព្រះភិក្ខុគ្រប់រូបអាចស្នាក់អាស្រ័យនិងសិក្សា

និងប្រព្រឹត្តប្រតិបត្តិតាមព្រះធម្មវិន័យ

ព្រោះវត្តមិនបានជារបស់បុគ្គលណាមួយសោះឡើយ ។

៦៤. វត្តអារាមរួមគ្នាកសាងមិនឈប់ឈរឡើយ ពិតៗ

តែយល់នូវព្រះធម្មវិន័យឬទេ ?

ព្រោះដូច្នោះ មានវត្តតែមិនមានព្រះធម្មវិន័យ

មានអ្នកដែលចង់បួស ហើយក៏បួស

តែមិនបានប្រព្រឹត្តប្រតិបត្តិតាមព្រះធម្មវិន័យ

ហើយនឹងទំនុបបម្រុងព្រះពុទ្ធសាសនាបានយ៉ាងដូចម្ដេចបាន ?

៦៥. សារៈសំខាន់របស់ជីវិត

មិនបាននៅត្រង់ការស៊ីដេកៗ ជាប់ជំពាក់ហើយក៏ស្លាប់ទៅ (នោះទេ)

ប៉ុន្តែនៅត្រង់ការដែលមានឱកាសបានស្ដាប់ព្រះធម៌សន្សំនូវការយល់ត្រូវឃើញត្រូវ ។

៦៦. សេចក្ដីគង់វង្ស សេចក្ដីស្ងប់សុខ ក៏ត្រូវតែមកពីមនុស្សល្អ ។

ព្រោះដូច្នោះ ការដែលឱ្យមនុស្សអាក្រក់ត្រឡប់មកជាមនុស្សល្អ

ក៏ដោយការដែលបានយល់នូវធម៌ ជាការឈ្នះនូវអំពើអាក្រក់ ដោយអំពើល្អ

ឈ្នះការមិនដឹង ដោយការដឹង ។

៦៧. មិនថាជានរណា អាយុប៉ុន្មាន

តែនៅពេលដែលបានស្ដាប់ហើយអាចនឹងយល់នូវពាក្យ

របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់បាន នេះគឺ ប្រយោជន៍ ។

៦៨. សម្រាប់ពុទ្ធបរិស័ទដែលពោលពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

គ្រប់ពាក្យ ជាទោសឬជាប្រយោជន៍ ? មិនបានពោលពាក្យរបស់អ្នកដទៃ

ប៉ុន្តែពេលតែពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងភាពល្អិតល្អន់

ដោយអ្នកដែលរួមគ្នាសិក្សាព្រះធម៌ និងសិក្សាជារៀងរហូត ។

នៅពេលនេះក៏នៅតែរួមគ្នាសិក្សាតទៅ

ដើម្បីឱ្យមានការយល់ដ៏ត្រឹមត្រូវតាមព្រះធម្មវិន័យ ។

៦៩. ពុទ្ធសាសនិកជនយល់នូវព្រះធម្មវិន័យ

ភិក្ខុក៏យល់នូវព្រះធម្មវិន័យ ប្រព្រឹត្តប្រតិបត្តិកម្ចាត់បង់នូវកិលេស

តាមភេទរបស់ខ្លួន ព្រះពុទ្ធសាសនានឹងស្រស់ស្អាតរុងរឿងប៉ុណ្ណាទៅ ?

តែតាមការពិតយុគសម័យនេះផ្ទុយគ្នា ជាយុគសម័យដែលអន់ថយ ។

៧០. ប្រសិនបើឃើញប្រយោជន៍របស់ការយល់នូវព្រះធម៌ពិតៗ

ក៏នឹងដឹងថា មិនមានអ្វីមានតម្លៃជាងការដែលបានស្តាប់នូវព្រះធម៌(ឡើយ) ។

ព្រោះហេតុថាត្រូវស្លាប់ជាពិតប្រាកដ

តែនឹងស្លាប់យ៉ាងល្ងង់មិនដឹងអ្វីដូចដើម

ឬថានឹងស្លាប់ទៅដោយបានយល់នូវធម៌ ?

៧១. ក្នុងមួយថ្ងៃៗ មិនប្រមាទក្នុងអកុសលធម៌ដែលកើតរហូត និងញឹកញាប់

និងមិនប្រមាទក្នុងកុសលសូម្បីតែបន្តិចបន្តួច

មួយខណៈក៏ខានមិនបាន ព្រោះខានទៅមួយខណៈ

នឹងសល់ប៉ុណ្ណា ? ក៏មិនមាន(ទេ) ។

ព្រោះដូច្នោះ ទោះបីជាបន្តិចបន្តួចក៏ជួយបន្ថែមឱ្យកុសលចម្រើនឡើង ។

៧២. រក្សាសន្សំបន្តិចម្តងៗ សន្សឹមៗ

ព្រោះព្រះធម៌ជារបស់ដែលមានប្រយោជន៍ក្នុងជីវិតពិតៗ

ក្នុងសង្សារវដ្ដ ព្រោះនឹងត្រូវដើរផ្លូវតទៅមុខទៀតវែងឆ្ងាយ ។

ព្រោះដូច្នោះ បើដើរក្នុងផ្លូវដែលត្រឹមត្រូវ ផ្លូវត្រង់

ក៏ជាប្រយោជន៍ មិនថារឿងណាៗទាំងអស់ ។

៧៣. បើនៅមានជីវិតរស់នៅ តែមិនបានយល់នូវព្រះធម៌

ក៏នៅទៅដើម្បីកិលេស ថែមនូវការជាប់ជំពាក់

បន្ថែមនូវការមិនដឹងតទៅជារឿយៗ ។

នៅមានអាយុវែង ក៏នឹងសន្សំកិលេសច្រើនឡើងទៅ

តែការដែលមានជីវិតដ៏ប្រសើរ គឺ

មានជីវិតនៅដើម្បីយល់នូវព្រះធម៌ ដើម្បីបញ្ញា(កើត)ប្រាកដ ។

៧៤. បើសិននឹងជាមនុស្សល្អ ក៏ជាមនុស្សល្អនៅជាតិនេះតែម្តងទៅ

ដល់ពេលដែលទៅដល់ជាតិមុខទៀត ក៏នៅមានសេចក្តីល្អយ៉ាងនេះ

មានការយល់នូវព្រះធម៌ដែលសន្សំនៅក្នុងចិត្ត

ដែលនឹងចម្រើនលូតលាស់តទៅ ជាមង្គលតទៅ ។

៧៥. នឹងញាប់ញ័រទេ បើជារឿងល្អដែលបានធ្វើហើយ ?

ព្រោះហេតុថា ត្រូវតែនាំផលដែលល្អនោះមកឱ្យ

បើមិនចូលចិត្តនូវអ្វីដែលមិនល្អ ក៏នឹងមិនធ្វើនូវអ្វីដែលមិនល្អ

ព្រោះដឹងថាអ្វីដែលមិនល្អទាំងអស់នោះ នឹងនាំផលដែលមិនល្អមកឱ្យ ។

៧៦. ពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

ធ្វើឱ្យយល់នូវអ្វីដែលមានពិត អ្វីណាជាហេតុ អ្វីណាជាផល ។

ព្រោះដូច្នោះ អ្នកដែលមិនយល់នូវការពិត ក៏ចេះតែគិតទៅផ្សេងៗ នានា

ប៉ុន្តែអ្នកដែលសន្សំមកដែលនឹងរឹងមាំគង់វង្សក្នុងហេតុនិងផល

ក៏នឹងមិនជឿក្នុងអ្វីដែលមិនមែនជាហេតុ មិនមែនជាផល ។

៧៧. កិលេស អកុសល ជារោគរបស់ចិត្តគំនិត

បើកិលេសដែលមានកម្លាំងខ្លាំង

ក៏ដូចជារោគដែលកម្រើកដែលធ្វើនូវការខូតខាតយ៉ាងខ្លាំង ។

ការសិក្សានិងអប់រំចម្រើនបញ្ញាដឹងនូវសភាវធម៌

តាមសេចក្តីពិតប៉ុណ្ណោះ ដែលដូចនឹងថ្នាំដែលរក្សាការពារចិត្តគំនិត

ឱ្យប្រាសចាករោគគឺ កិលេស ។

៧៨. ក្នុងរឿងដែលចម្រើនកុសល ឬធ្វើសេចក្តីល្អ

ខ្វះខាតនូវការព្យាយាមមិនបានឡើយ

ព្រោះហេតុថា នឹងត្រូវល្មើសចូលក្នុងក្រសែអកុសល

ល្មើស(ចូល)ការពេញចិត្ត ការសុខស្រួលគ្រប់ប្រការ

ដើម្បីឱ្យកុសលនោះៗ សម្រេច ។

៧៩. ជាភិក្ខុ ដើម្បីកម្ចាត់បង់នូវកិលេស

ពាក្យនេះតែមួយគឺ ដើម្បីកម្ចាត់បង់នូវកិលេស ។

តែបើប្រព្រឹត្តទៅដើម្បីសន្សំនូវកិលេស នេះមិនត្រឹមត្រូវទេ

មិនមែនជាភិក្ខុឡើយ នរណាគាំទ្រឱ្យប្រព្រឹត្តអ្វីដែលខុស

នោះជាការជួយគ្នាបំផ្លាញព្រះពុទ្ធសាសនា ។

៨០. ភិក្ខុដែលមិនបានប្រព្រឹត្តប្រតិបត្តិតាមព្រះធម្មវិន័យ

មិនមែនជាបព្វជិត មិនមែនជាអ្នកកម្ចាត់កិលេស

តែពេលដែលជាបព្វជិតហើយ

ត្រូវតែដឹងថា មានជីវិតដូចគ្រហស្ថមិនបានឡើយ ។

៨១. មួយពាក្យៗ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

នឹងបើកបង្ហាញឱ្យដឹងថា យើងមិនបានដឹងមកជាយូរសែនយូរណាស់មកហើយ

និងមិនមានផ្លូវដែលនឹងដឹងបានឡើយ បើសិនជាមិនមានការស្តាប់នូវព្រះធម៌ ។

ដោយហេតុនេះ ការដែលយើងមានឱកាសបានយល់នូវព្រះធម៌

ទើបជាឱកាសដ៏ប្រសើរបំផុត ។

៨២. ការដែលយើងស្តាប់ពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ដោយសេចក្តីគោរព

ជាការទំនុកបម្រុងព្រះពុទ្ធសាសនា ។

យើងធ្លាប់បម្រើអ្នកដទៃ ញាតិ បងប្អូន ឬនរណាក៏ដោយ

តែមិនមានអ្វីដែលនឹងប្រសើរស្មើនឹងការដែលបានបម្រើទំនុកបម្រុង

ព្រះពុទ្ធសាសនា ព្រោះជាអ្វីដែលមានគុណតម្លៃលើអ្វីៗយ៉ាងដទៃទៀត

នឹងធ្វើឱ្យអ្នកដទៃមានឱកាសបានយល់ ជាមួយគ្នាតទៅ ។

៨៣. នរណាត្រូវការយំយែកខ្លះ នរណាត្រូវការខូចចិត្តខ្លះ

នរណាត្រូវការភាពជាទុកខ្លះ ? តែបើមានការរីករាយពេញចិត្ត

នៅពេលដែលរបស់ជាទីពេញចិត្តព្រាត់ប្រាសបាត់បង់ទៅ

ជាធម្មតា ក៏ត្រូវមានការបាត់បង់

មានការសោកសៅខូចចិត្ត ។

៨៤. អ្វីដែលប្រសើរបំផុតក្នុងជីវិត

មិនមែន លាភ យស ការសរសើរ សុខ ណាៗសោះឡើយ

តែជាការយល់ត្រូវ ឃើញត្រូវ ។

កិលេសដែលមានច្រើននៅក្នុងសង្សារវដ្ត ម្នាក់ៗ ប្រមាទមិនបានឡើយ

អាចនឹងសន្សឹមៗ កាត់បន្ថយម្តងបន្តិចៗ

ក៏ដោយការយល់ត្រូវ ឃើញត្រូវ ។

៨៥. ការប្រព្រឹត្តផ្សេងៗ តគ្នាមក ដោយមិនយល់ហេតុផល

នឹងត្រឹមត្រូវឬទេ ? មិនត្រឹមត្រូវទេ ។ មិនចាំបាច់តាមនរណាទាំងអស់ដែលខុស

តែជាអ្នកដែលត្រូវតែមួយរូប មួយរូបៗ ច្រើនទៅ នៅក្នុងពិភពលោក

ពិភលោកក៏ចម្រើន ព្រោះការយល់ដែលត្រឹមត្រូវ ។

៨៦. កុសលធម៌ ក្លាហាននឹងធ្វើនូវអ្វីដែលល្អ ខ្មាស់អៀនដែលនឹងធ្វើនូវអ្វីដែលមិនល្អ

មិនក្លាហានដែលនឹងធ្វើនូវអ្វីដែលមិនល្អ ព្រោះឃើញទោសនូវអ្វីដែលមិនល្អ ។

៨៧. ប្រសិនបើរាល់គ្នាមានមេត្តា ភាពជាមិត្តជាសម្លាញ់

ជួយគ្នាធ្វើប្រយោជន៍ នឹងក្តៅក្រហាយឬទេ ? ក៏មិនក្តៅក្រហាយ ។

តែហេតុអ្វីក្តៅក្រហាយ ? ក៏ព្រោះមិនបានជាមិត្ត ជាសម្លាញ់នឹងគ្នា

យ៉ាងពិតប្រាកដ(ឡើយ) (ខ្វល់ខ្វាយ)ចង់បានតែប្រយោជន៍របស់ខ្លួន ចង់បាន

ធ្វើនូវទុច្ចរិតក៏ធ្វើ បៀតបៀនអ្នកដទៃក៏ធ្វើ

ព្រោះមិនឃើញទោស ។

៨៨. កិលេសដែលជាគ្រឿងសៅហ្មងរបស់ចិត្ត

មិនមែនមានត្រឹមតែលោភៈ មិនមែនមានត្រឹមតែទោសៈ

តែនៅមាន មោហៈ ការមិនដឹងផងដែរ

ដែលការមិនដឹងជាឫសគល់នៃកិលេសទាំងឡាយផងដែរ ។

៨៩. ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់មានព្រះមហាករុណាដល់សត្វលោក

ឱ្យដឹងថាអ្វីត្រឹមត្រូវ អ្វីខុស ដើម្បីនឹងមិនបានធ្វើនូវអ្វីដែលខុស

ព្រោះអ្វីដែលខុស ជាទោសដល់អ្នកប្រព្រឹត្ត ។

៩០. បានស្តាប់ព័ត៌មានរឿងរ៉ាវរបស់ការប្រព្រឹត្តទុច្ចរិត ប្រព្រឹត្តខុសផ្សេងៗ

ដឹងហើយថា ព្រោះគេមិនមានបញ្ញា

បើមានបញ្ញាការយល់ត្រូវ ឃើញត្រូវ នឹងជាយ៉ាងនោះមិនបានឡើយ ។

ព្រោះដូច្នោះ ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង

ធ្វើឱ្យកើតបញ្ញា ការយល់ដែលត្រឹមត្រូវ ។

៩១. ការស្តាប់ព្រះធម៌យល់ឡើង មិនបានធ្វើនូវការក្តៅក្រហាយដល់អ្នកណាឡើយ

សូម្បីតែខ្លួនឯង បើធ្លាប់ខឹងក្រោធហើយ ដឹងថាខឹងក្រោធមិនល្អ

បញ្ញាឃើញទោសនៃសេចក្តីក្រោធខឹង

សេចក្តីក្រោធខឹងក៏ថយចុះបន្តិចម្តងៗ

តែបើនៅតែមិនដឹងទោស ក៏នៅតែខឹងយ៉ាងហ្នឹងឯង ។

៩២. បុគ្គលណាខឹងតបជាមួយបុគ្គលអ្នកខឹង

ឈ្មោះថាជាអ្នកអាក្រក់ជាងបុគ្គលដែលខឹងមុន

ព្រោះហេតុថា បុគ្គលអ្នកខឹងជាមនុស្សអាក្រក់

ព្រោះមានអកុសលចិត្តកើតឡើង

តែបុគ្គលអ្នកខឹងតប ក៏ជាអ្នកដែលឃើញហើយថាជាអកុសល

ក៏នៅតែមានអកុសលចិត្តកើតឡើងទៅជាមួយដែរ ។

៩៣. យើងមិនល្អ ហើយមានអ្នកដទៃមកប្រាប់យើងថាយើងមិនល្អ

ហើយក៏ដឹងថាធ្វើយ៉ាងដូចម្តេចនឹងបានល្អ

បុគ្គលនោះ គឺជាបុគ្គលជាមិត្តដ៏ល្អជាមួយយើង ។

៩៤. មិនមានការដឹងមុនសោះឡើយ

សូម្បីតែពេលឥឡូវនេះ ក៏មិនមាននរណាដឹងទុកមុន ។

ព្រោះដូច្នោះ បើមានការយល់នូវរឿងកម្មដែលជាហេតុ

និងយល់នូវផលរបស់កម្ម ក៏នឹងមិនប្រព្រឹត្តកម្មដែលមិនល្អ

ព្រោះឧទាហរណ៍មានឱ្យឃើញស្រាប់ហើយ គឺ

ឧទាហរណ៍អ្នកដែលទទួលផលរបស់កម្មដែលមិនល្អ ។

៩៥. ក្នុងជីវិតធ្វើល្អ ព្រោះដឹងថានឹងកើតតទៅទៀតសែនយូរណាស់ក្នុងសង្សារវដ្ត

នឹងជាអ្វី ស្រេចតែការសន្សំ ។

ព្រោះដូច្នោះ មនុស្សតទៅមិនមែនអ្នកនេះ តែបន្តពីអ្នកនេះ

នឹងជាយ៉ាងណាក៏ស្រេចតែអ្នកនេះនៅក្នុងជាតិនេះ

បើយល់ខុសក៏សន្សំការយល់ខុសនោះទៅជាតិខាងមុខទៀត

ល្អទេ ? មិនល្អទេ ។ អន្តរាយប៉ុណ្ណាទៅចំពោះការយល់ខុស ?

ជាតំណរបស់សង្សារវដ្ត ចេញទៅមិនបានឡើយ ។

៩៦. អ្វីដែលកន្លងទៅហើយ មិនអាចនឹងកែខៃបាន

តែតទៅនេះនឹងធ្វើអ្វីដែលត្រឹមត្រូវ

ព្រោះដឹងថាអ្វីដែលខុសក៏មិនធ្វើ

នេះគឺ បញ្ញា ។ ប្រសិនបើជាអ្នកដែលមានបញ្ញាក៏នឹងមិនធ្វើនូវអ្វីដែលខុស

ព្រោះបញ្ញានាំទៅនូវកិច្ចទាំងពួងដែលជាកុសល ។

៩៧. បើសិនជាតិនេះយល់ឃើញខុស ជាតិតទៅមុខទៀតក៏យល់ឃើញខុស

តែបើជាតិនេះបានសន្សំនូវការយល់ឃើញដែលត្រឹមត្រូវ ត្រូវតែជាបច្ច័យ

ដល់ពេលបានឮពាក្យដែលត្រឹមត្រូវ ក៏អាចយល់ឃើញត្រឹមត្រូវបាន ។

ព្រោះពាក្យពិតទាំងអស់ជាពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

មិនថានរណានឹងពោល ព្រោះជាពាក្យដែលត្រឹមត្រូវ ។

៩៨. ឃើញប្រយោជន៍ ឃើញគុណតម្លៃរបស់សេចក្តីល្អ

ថាជាអ្វីតែមួយ(គត់)ដែលនៅពេលសន្សំបន្តិចម្តងៗ សន្សឹម ៗ បន្ថែមច្រើនឡើង

ក៏អាចលះបង់នូវផ្លូវដែលជាផ្នែកខាងអកុសលបាន ។

៩៩. អំពើល្អមិនធ្វើឱ្យកើតបញ្ហាណាៗទាំងអស់

ប៉ុន្តែអំពើអាក្រក់ទាំងអស់ជាបច្ច័យធ្វើអោយកើតបញ្ហាតាំងតែតូច

រហូតដល់បញ្ហាធំបាន ។

១០០ បញ្ញា ឃើញត្រឹមត្រូវថា ល្អគឺល្អ អាក្រក់គឺអាក្រក់

ត្រូវគឺត្រូវ ខុសគឺខុស បញ្ញាត្រង់ណាស់

ព្រោះហេតុដូច្នោះ បញ្ញាមិនមានផ្លូវដែលនឹងនាំទៅរកការប្រព្រឹត្តមិនល្អបានឡើយ ។

១០១. ទាំងគ្រហស្ថនិងបព្វជិត បើសិនជាមិនយល់នូវព្រះធម្មវិន័យ

ក៏ជួយគ្នាបំផ្លាញព្រះពុទ្ធសាសនា

មិនជួយគ្នាទំនុកបម្រុងព្រះពុទ្ធសាសនា

ព្រោះដូច្នោះ ការយល់នូវព្រះធម៌ជារឿងដែលសំខាន់បំផុត

ដែលនឹងទំនុកបម្រុងព្រះពុទ្ធសាសនាបាន ។

១០២. ការសិក្សាព្រះធម៌ជាការកម្ចាត់បង់នូវការមិនចេះ មិនដឹង

អ្នកដែលមិនសិក្សាព្រះធម៌ មិនស្តាប់ព្រះធម៌

ព្រោះគេមិនដឹងថា គុណតម្លៃដ៏ខ្ពស់បំផុតក្នុងជីវិតគ្រប់ជាតិ

ក៏គឺ បានមានការយល់ឃើញដែលត្រឹមត្រូវ ។

១០៣. គួរឱ្យសោកស្តាយពេលវេលាដែលទៅប្រព្រឹត្តប្រតិបត្តិខុស ជំនួសពេលវេលា

ស្តាប់ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដូចជាបុគ្គល

ក្នុងសម័យពុទ្ធកាលដែលបានទៅគាល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

នៅឯព្រះវិហារជេតពន ព្រះវិហារវេឡុវ័ន ដើម្បីស្តាប់ព្រះធម៌ ។

១០៤. តែមួយពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ជ្រាលជ្រៅដ៏ក្រៃលែង

ធ្វើឱ្យអ្នកដែលឃើញគុណតម្លៃបន្តិចម្តងៗ ពិចារណាជាសន្សឹមៗ យល់

ហើយការយល់នោះឯង នឹងធ្វើអោយជាមនុស្សល្អ

ព្រោះបញ្ញាដឹងថា អ្វីត្រូវ អ្វីខុស អ្វីជាទោស

អ្វីជាប្រយោជន៍ ។

១០៥. ជាបុគ្គលនេះ បានតែជាតិនេះតែម្តង(ប៉ុណ្ណោះ)។

ស្លាប់ទៅហើយជាបុគ្គលនេះទៀតមិនបានឡើយ ។

ព្រោះដូច្នោះ មុនពេលដែលស្លាប់ ជាមនុស្សល្អ ល្អជាងឬទេ ? និង

យល់នូវការពិតរបស់អ្វីដែលមានពិតក្នុងលោកតាមសេចក្តីពិត ។

១០៦. ហ៊ាននឹងធ្វើខុស កិលេសពិតប្រាកដ

ហ៊ានដែលនឹងធ្វើខុសតទៅទៀត ក៏ជាកិលេស

ប៉ុន្តែបើដឹងថាអ្វីណាជារឿងដែលត្រឹមត្រូវ ហើយហ៊ាននឹងធ្វើនូវអ្វីដែលត្រឹមត្រូវ

នោះឯងជាប្រយោជន៍ដ៏ក្រៃលែង ។

១០៧. មនុស្សល្អ មិនបួសក៏បានដែរ មិនបានទៅបំផ្លាញព្រះរតនត្រ័យ

មិនបានធ្វើឱ្យព្រះរតនត្រ័យសៅហ្មងឡើយ

ព្រោះថាជាមនុស្សល្អ ធ្វើល្អ

ប៉ុន្តែបើបានបួសហើយមិនប្រព្រឹត្តប្រតិបត្តិតាមព្រះធម្មវិន័យ

មិនសិក្សាព្រះធម៌ផងដែរទៀតនោះ ជាទោសដ៏ធំក្រៃលែង ។

១០៨. កុសលល្អស្អាត អកុសលមិនល្អស្អាត

បើសិនបញ្ញាអាចនឹងយល់ត្រូវ ឃើញត្រូវ ថាអ្វីជាប្រយោជន៍

បញ្ញាក៏នាំទៅនូវកុសលទាំងពួង

មិនមានផ្លូវដែលមនុស្សក្នុងប្រទេសជាតិនឹង(ប្រព្រឹត្ត)ទុច្ចរិតថែមឡើង(ឡើយ)

បើមានការយល់ដែលត្រឹមត្រូវថែមឡើង ។

១០៩. កែបញ្ហាស្រពិចស្រពិល ដោយការមិនដឹង កែមិនសម្រេច(ឡើយ) ។

តែបើមានការយល់នូវព្រះធម៌ មានការយល់នូវព្រះធម៌គង់វង្ស(ប្រាកដប្រជា)ថែមឡើង

មនុស្សល្អថែមឡើង មនុស្សអាក្រក់ថយចុះ ប្រទេសជាតិក៏ចម្រើនគង់វង្សឡើង ។

១១០. នរណាដឹងនូវកិលេសល្អិតស្មើនឹងព្រះសម្មាសម្ពុទ្ធជាម្ចាស់ខ្លះ ?

អ្វីដែលមិនសម មិនគួរ ដែលអ្នកដទៃមិនឃើញ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងថាអ្វីនោះឯង

ជាអ្វីដែលមិនសមគួរ

ព្រោះហេតុថា រមែងនាំមកនូវកិលេសថែមឡើង ។

១១១. ឃើញប្រយោជន៍របស់សេចក្តីល្អច្រើនប៉ុណ្ណា

បើឃើញថាសេចក្តីល្អមានប្រយោជន៍ណាស់

មានឬ(ទេ) ដែលនឹងរោក្នុងការធ្វើនូវសេចក្តីល្អ ?

ព្រោះដូច្នោះ ក៏ប្រព្រឹត្តទៅតាមការយល់ទាំងអស់

មិនស្ថិតថេរនៅក្រោម(ការ)បង្គាប់បញ្ជារបស់នរណាទាំងអស់ ។

១១២. ទោសរបស់អ្នកដែលបំផ្លាញពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

ប៉ុណ្ណា(ទៅ)? មិនមែនយល់ឃើញខុសតែចំពោះខ្លួនឯង

តែថែមទាំងផ្សព្វផ្សាយការយល់ដែលខុសៗ ឱ្យអ្នកផ្សេងវង្វេងផ្លូវ

ស្មើនឹងការដែលបំផ្លាញពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

១១៣. នឹងបាត់បង់ លាភ យស ក៏ជារបស់ធម្មតា

តែការដែលយល់ខុស គួរតែប្រញាប់យ៉ាងលឿន នឹងលះបង់ចោល

មិនរក្សាសន្សំទុកតទៅទៀត ព្រោះហេតុថា បើសន្សំតទៅទៀត

ក៏ជាទោសនិងមិនអាចនឹងលះបង់បាន ។

១១៤. អ្វីដែលសំខាន់បំផុតដែលនឹងទំនុកបម្រុងព្រះពុទ្ធសាសនា

មិនមែនជា របស់របរ ការកសាងធំធេង (ឡើយ) ប៉ុន្តែត្រូវតែជាការ

យល់នូវព្រះធម៌ប៉ុណ្ណោះដែលនឹងទំនុកបម្រុងរក្សាព្រះពុទ្ធសាសនាទុកបាន ។

១១៥. អន្តរាយដែលមើលមិនឃើញជាងអន្តរាយដទៃ ក៏គឺ

ពុទ្ធសាសនិកជនដែលយល់ថាខ្លួនឯងគោរពព្រះពុទ្ធសាសនា

តែមិនបានយល់នូវព្រះធម៌ ព្រោះដូច្នោះ នៅពេលមិនយល់ព្រះធម៌

ក៏បណ្តែតបណ្តោយតាមអ្វីដែលខុសទាំងអស់ ដោយមិនដឹងថានោះជាភ័យ

ដែលជួយគ្នាបំផ្លាញព្រះពុទ្ធសាសនា ។

១១៦. មានសំណាក់បដិបត្តិ ប្រព្រឹត្តប្រតិបត្តិដោយមិនបានយល់នូវធម៌ឡើយ

នោះឯងគឺវង្វេងផ្លូវ និងធ្វើឱ្យអ្នកដទៃយល់ខុសផងដែរ ។

១១៧. ព្រះភិក្ខុផ្ទុយពីគ្រហស្ថ ប៉ុណ្ណេះក៏តបបានគ្រប់ ៥ (ប្រការ)

ព្រោះថាគ្រហស្ថរីករាយនូវមាសនិងប្រាក់

តែបុគ្គលដែលនឹងបួស លះមាសនិងប្រាក់ លះមានន័យថាមិនត្រេកអរ

ព្រោះដូច្នោះ បើត្រេកអរនូវមាសនិងប្រាក់នៅឡើយ

ក៏មិនមែនព្រះភិក្ខុនៃព្រះធម្មវិន័យឡើយ ។

១១៨. ដរាបណានៅមានអ្នកយកលុយទៅពាក់ព័ន្ធនឹងព្រះភិក្ខុ

អ្នកនោះមិនមែនជាមិត្តជាមួយនឹងព្រះភិក្ខុនោះ(យ៉ាង)ប្រាកដណាស់

ព្រោះធ្វើឱ្យអ្នកដែលកំពុងកម្ចាត់បង់នូវកិលេសត្រូវជាប់ជំពាក់

ព្រោះកិលេស ។

១១៩. ព្រះភិក្ខុក្នុងធម្មវិន័យ នៅបានព្រោះបច្ច័យ

(គឺ គ្រឿងដែលអាស្រ័យរបស់ជីវិត) ៤ យ៉ាង

គ្រឿងស្លៀកដណ្តប់ អាហារ

កន្លែងស្នាក់អាស្រ័យនៅ និងថ្នាំរក្សារោគ ។

ល្មមឬទេដែលនឹងមានជីវិតរស់នៅដើម្បីកម្ចាត់បង់នូវកិលេស ?

តែបើរីករាយនូវមាសនិងប្រាក់ ក៏បន្ថែមកិលេស

មិនបានកម្ចាត់បង់នូវកិលេស ។

១២០. បើមិនមែនជាព្រះភិក្ខុនៅក្នុងធម្មវិន័យ

សូម្បីអង្គុយបរិភោគអាហាររួមជាមួយនឹងភិក្ខុដទៃ

ក៏ដូចអាការលួច ព្រោះអាហារដែលគេឱ្យ

ឱ្យសម្រាប់អ្នកដែលកាត់បង់នូវកិលេស អោយអ្នកដែលប្រព្រឹត្តប្រតិបត្តិ

តាមព្រះធម្មវិន័យសិក្សាធម៌យល់

តែខ្លួនឯងមិនមានលក្ខណៈយ៉ាងនោះ

មិនមានគុណដើម្បីនឹងទទួលអាហារយ៉ាងនោះ

ក៏ដូចជាការលួចបរិភោគអាហារខណៈដែលបរិភោគ ។

១២១. ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ទទួលមាសនិងប្រាក់ឬទេ ?

ហើយព្រះអង្គទ្រង់មានព្រះជន្មបានយ៉ាងដូចម្ដេច ?

ព្រះភិក្ខុដែលបួសតាមព្រះធម្មវិន័យ ទទួលមាសនិងប្រាក់ឬទេ ?

ព្រះសារីបុត្រ ព្រះមោគ្គលាន

ព្រះអស្សជិ ព្រះបុណ្ណមន្តានីបុត្រ

ព្រះភិក្ខុទាំងនៅក្នុងសម័យព្រះពុទ្ធកាល ទទួលមាសនិងប្រាក់ឬទេ ?

ហើយលោកម្ចាស់ទាំងអស់នោះនៅបានយ៉ាងដូចម្ដេច ? រស់នៅបានដោយគុណ(គឺ)សេចក្ដីល្អ ។

១២២. គ្រហស្ថនៅគ្រានោះដែលបានឃើញទង្វើរបស់ព្រះភិក្ខុ

ដែលទទួលមាសប្រាក់ ក៏ប្រាប់ទោសឱ្យព្រះភិក្ខុនោះយល់ ឱ្យត្រឹមត្រូវថា

នេះជាទោសយ៉ាងខ្លាំង ព្រោះលះហើយមែនទេ ?

នឹងទទួលទៀតបានយ៉ាងដូចម្ដេចទៅ ? នៅពេលដែលប្រាប់ពីទោសហើយក៏តិះដៀលផងថា

ប្រព្រឹត្តយ៉ាងនេះមិនសមរម្យ មិនសមគួរដល់ភេទបព្វជិត

ហើយក៏ស្ថាបនា គឺប្រកាសអោយដឹងគ្រប់គ្នាថា

ការប្រព្រឹត្តយ៉ាងនេះមិនត្រឹមត្រូវ ។

នេះគឺ(ជា)គ្រហស្ថដែលទំនុកបម្រុងរក្សាពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

ដោយការដែលពោលដល់នូវអ្វីដែលត្រឹមត្រូវ

ហើយក៏ចង្អុលបង្ហាញទោសក្នុងរឿងដែលខុស ។

១២៣. ជឿជាក់ទុកចិត្តក្នុងពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

ព្រោះហេតុថា ជាអ្នកដែលត្រាស់ដឹងនូវការពិត

មិនមានពាក្យកុហក មិនមានពាក្យបោកបញ្ឆោត

មិនមានពាក្យប្រាថ្នាអាក្រក់ ចេញពីគ្រប់ពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

១២៤. ឃើញប្រយោជន៍របស់ការស្តាប់ព្រះធម៌ឬទេ ?

ប្រសិនបើស្តាប់ទៀត ក៏នឹងយល់ច្រើនឡើងៗ ថែមទៀត

បើបានឃើញប្រយោជន៍ហើយ នឹងស្តាប់ជាប្រាកដ

ព្រោះថា យើងស្តាប់រឿងដទៃមកជាច្រើនហើយ

តែការដែលបានស្តាប់ព្រះធម៌ជាការដែលបានស្តាប់រឿងដែលមានប្រយោជន៍

លើសអ្វីៗ ដែលយើងធ្លាប់ស្តាប់មកទាំងអស់គ្រប់យ៉ាង ។

១២៥. អ្នកដែលមិនយល់នោះមានច្រើន ទើបមិនបានធ្វើនូវអ្វីដែលត្រឹមត្រូវ ។

ព្រោះដូច្នោះ ផ្លូវតែមួយគឺ

មានផ្លូវណាដែលនឹងជួយឱ្យមនុស្សបានយល់យ៉ាងត្រឹមត្រូវ ក៏ធ្វើ(ឱ្យ)មិនរោ

ព្រោះនរណានឹងដឹងថានឹងលាចាកលោកនេះទៅថ្ងៃណា ?

១២៦. ហេតុអ្វីទើបជាអកុសលផ្សេងៗ? ព្រោះមិនដឹង

ដូចជា ប្រសិនបើមិនដឹង ត្រូវតែជាប់ជំពាក់ជាពិតប្រាកដ

ព្រោះមិនដឹងសេចក្តីពិតរបស់អ្វីដែលប្រាកដថា

ត្រឹមតែកើតប្រាកដហើយក៏រលត់ទៅអស់ប៉ុណ្ណោះ ។

១២៧. ស្តាប់ព្រះធម៌ ដើម្បីលះការមិនដឹង

ហើយក៏រីករាយដែលមានឱកាសបានយល់សូម្បីត្រឹមតែបន្តិចបន្តួច

ក៏នៅតែល្អជាងការដែលមិនដឹងអ្វីសោះឡើយ ហើយបើស្តាប់ញយៗ ឡើង

មានឬដែលនឹងមិនយល់ឡើងជាសន្សឹមៗ ?

ព្រោះជារឿងលះការមិនដឹង ។

១២៨. មិនបោះបង់ធុរៈក្នុងការសិក្សាព្រះធម៌ឱ្យយល់ ។

នៅពេលដែលយល់ព្រះធម៌ ក៏អាចនឹងដឹងបានថា ការប្រព្រឹត្តណាៗ

ដែលនឹងជាការរក្សាព្រះពុទ្ធសាសនាទុកបាន

ត្រូវតែជាការប្រព្រឹត្តដែលត្រឹមត្រូវ បើសិនជាការប្រព្រឹត្តដែលខុស

បំផ្លាញព្រះពុទ្ធសាសនា មិនមែនរក្សាព្រះពុទ្ធសាសនា(ឡើយ)។

១២៩. ប្រសិនបើជាផ្លូវដែលខុស ក៏ចូរកុំឱ្យបានប្រតិបត្តិឡើយ

ព្រោះហេតុថាមិនបានកើតនូវប្រយោជន៍អ្វីឡើយ

ក្រៅតែពីនឹងប្រកាន់ក្នុងខប្រតិបត្តិដែលខុសនោះកាន់តែខ្លាំងឡើង ។

១៣០. មនុស្សមិនល្អនោះមានច្រើនជាពិតប្រាកដ ប៉ុន្តែសម្រាប់បុគ្គលដែលមានបញ្ញាហើយ

ទោះបីអ្នកដទៃនឹងកើតអកុសល

តែខ្លួនឯងក៏អាចដែលនឹងមិនកើតអកុសលបាន ។

១៣១. ព្រះធម៌ ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់

រុងរឿងនៅពេលដែលមានអ្នកយល់ត្រូវ

តែបើមិនពោលពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ឱ្យយល់

មិនមែនព្រះពុទ្ធសាសនារុងរឿង(ឡើយ)

ត្រឡប់មកដួលរលំ ត្រូវបំផ្លាញដោយការដែលយល់ខុស ។

១៣២. ស្តាប់ព្រះធម៌ព្រោះដឹងថាការមិនចេះ មិនដឹង មានច្រើនណាស់

ប្រសិនបើមិនបានស្តាប់ព្រះធម៌ ការមិនដឹងក៏រឹងរឹតតែចម្រើនច្រើនឡើងថែមទៀត

ហើយនឹងនៅក្នុងសង្សារវដ្តទៀតយូរប៉ុណ្ណា ?

១៣៣. អកុសលធម៌ជាឫស ជាពូជ ដែលពិបាកស្លាប់ ពិបាករលត់

បើមិនអប់រំចម្រើនបញ្ញាដែលនឹងដឹងនូវលក្ខណៈរបស់សភាវធម៌

ដោយពិតប្រាកដច្បាស់លាស់ ដោយល្អិតល្អន់ ដោយត្រឹមត្រូវពិតៗ

អកុសលធម៌ទាំងឡាយក៏មិនអាចនឹងរលត់បានដែរ ។

១៣៤. ទោះបីជានឹងមានទ្រព្យសម្បត្តិមាសប្រាក់ច្រើនសម្បើមមហាសាល

ក៏នៅតែជាទុក្ខ ស្តែង(ឱ្យឃើញ)ថា ទុក្ខព្រោះនៅជាប់ជំពាក់

បើសិនជាអាចលះបង់នូវអ្វីដែលជាប់ជំពាក់គ្រប់យ៉ាងបាន

នឹងមិនមានសេចក្តីទុក្ខឡើយ តែដរាបណានៅមានការជាប់ជំពាក់

មិនថាទៅនឹងនៅក្នុងអ្វីទាំងអស់ ក៏រមែងនាំមកនូវសេចក្តីទុក្ខ ។

១៣៥. បញ្ញា ការយល់ត្រូវ ឃើញត្រូវ ជារបស់ដែលល្អ

ការមិនដឹង ជារបស់ដែលមិនល្អ

បើសិនជាអាចយល់នូវការពិតក្នុងជីវិតប្រចាំថ្ងៃ

តាំងតែពីកើតរហូតដល់ស្លាប់បន្ថែមឡើង ជីវិតក៏ត្រូវតែជាសុខបន្ថែមឡើង ។

១៣៦. ប្រសិនបើឃើញថា ព្រះពុទ្ធសាសនាល្អ គួរសិក្សា

អ្នកនោះក៏ត្រូវសិក្សាផងដែរ មិនមែនចង់តែឱ្យអ្នកដទៃសិក្សា

តែខ្លួនឯងមិនសិក្សា ជាពិសេលចង់អោយក្មេងសិក្សា

តែមនុស្សចាស់មិនសិក្សា ។ បើមនុស្សចាស់មិនសិក្សា តើក្មេងនឹងសិក្សាចេញពីនរណា ?

១៣៧. ព្រះធម៌បញ្ជាក់ហើយបញ្ជាក់ទៀតថា ម្នាក់ៗមានកិលេសច្រើនពិត ៗ

ដើម្បីនឹងបានមិនប្រមាទក្នុងការអប់រំចម្រើនកុសលកម្ចាត់បង់នូវកិលេស

ព្រោះឃើញទោសរបស់កិលេស ទើបមានការចម្រើនកុសល ច្រើនឡើង ។

១៣៨. អ្នកដែលធ្លាប់មិនប្រយ័ត្នពាក្យសម្ដី និយាយស្ដីស្ដាប់មិនបានឡើយ ។

ដឹងឬទេថា ខណៈនោះអ្នកស្ដាប់ក្ដៅក្រហាយ ?

អ្នកនិយាយមិនស្ដាប់ឡើយ មានកម្លាំងរបស់កិលេសដែលនឹងនិយាយ

តែមិនបានដឹងឡើយថាអ្នកដទៃក្ដៅក្រហាយព្រោះពាក្យនោះ ។

១៣៩. ខណៈដែលមិនខឹងក្រោធ នឹងមានសេចក្ដីក្រោធខឹងកើតរួមជាមួយមិនបានឡើយ ។

ខឹងល្អទេ ? មិនល្អទេ ។ ព្រោះសភាពដែលខឹងកើតឡើងពេលណា

បំផ្លាញចិត្តពេលនោះ ជាសត្រូវខាងក្នុង សត្រូវខាងក្នុងកើតពេលណា

ធ្វើបាបចិត្តភ្លាមមួយរំពេច នៅពេលដែលចិត្តមិនល្អហើយ កាយក៏មិនល្អ វាចាក៏មិនល្អ ។

១៤០. គេអាក្រក់ រឿងរបស់គេ តែយើងខណៈនោះជាអ្វី ?

នៅជាមិត្តឬទេ ? គឺមិនមែនជាសត្រូវ

ទោះ(បី)គេមកអាក្រក់ជាមួយយើងប៉ុណ្ណា

យើងក៏អាចមិនជាសត្រូវបាន គឺមិនគិតអាក្រក់ជាមួយនឹងគេ ។

នេះជាសេចក្ដីល្អរបស់យើង ។

១៤១. គេជេរយើង ព្រោះគេខឹងក្រោធនឹងយើង

បើសិនជាគេជេរយើង ហើយយើងខឹងនឹងគេ

យើងនេះឯងដែលបាត់បង់ប្រយោជន៍ ព្រោះជាអកុសល

គេខឹងនឹងយើង គេក្ដៅក្រហាយ

យើងខឹងនឹងគេ យើងក៏ក្ដៅក្រហាយដូចគ្នា ។

១៤២. ចាប់ផ្ដើមឃើញចិត្តអ្នកដែលធ្វើអកុសលកម្មបានហើយ

ព្រោះគេបានសន្សំហេតុដែលមិនល្អទុកមក

ហើយនៅទីបំផុត អកុសលកម្មដែលគេធ្វើ

ក៏រមែងនឹងជាហេតុឱ្យគេបានទទួលផលដែលមិនល្អក្នុងកាលខាងមុខ ។

១៤៣. ជារឿងធម្មតាពិត ៗ សម្រាប់ពាក្យនិន្ទានិងសរសើរ

នៅពេលដែលជារឿងធម្មតាយ៉ាងនេះ នរណាខាតពេលក្ដៅក្រហាយចិត្ត

ញាប់ញ័រ ក៏ជាអ្នកមិនឆ្លាត

ព្រោះហេតុថា មិនដឹងនូវសភាវធម៌ដែលជាធម្មតារបស់លោក ។

១៤៤. ការប្រព្រឹត្តដែលខុសទាំងអស់

មកពីការដែលមិនដឹង ។ ហើយនរណានឹងដឹងថាមិនដឹង

បើសិនជាមិនបានស្ដាប់នូវពាក្យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ?

ព្រោះដូច្នោះ ព្រះធម៌មិនបាន(ជា)សាធារណៈ គឺ មិនគ្រប់គ្នាទូទៅទាំងអស់ទេ

តែត្រូវសម្រាប់តែអ្នកដែលសន្សំមកនឹងឃើញគុណតម្លៃ

និងសិក្សាដោយសេចក្ដីគោរពពិត ៗ ដែលដឹងថាគ្រប់ពាក្យរបស់ព្រះអង្គ

ដើម្បីតែការកាត់បង់នូវកិលេសទាំងគ្រហស្ថនិងទាំងបព្វជិត ។

១៤៥. អ្វីដែលល្អមានតម្លៃ ទោះបីជាតិចក៏មានតម្លៃ

ខុសពីរបស់ដែលច្រើនតែមិនមានគុណតម្លៃ មិនមានប្រយោជន៍

សូម្បីច្រើន ក៏មិនមានតម្លៃ មិនមានប្រយោជន៍ ។

ព្រោះដូច្នោះ បញ្ញាជាមួយនឹងអកុសលធម៌ ប្រៀបធៀបគ្នាមិនបានឡើយ ។

១៤៦. បញ្ញាអាចយល់ត្រឹមត្រូវ

ថាអកុសល ជាទោសដ៏ពិតប្រាកដ

ក្នុងខណៈដែលអកុសលចិត្តកើត ធ្វើបាបនរណា ?

ធ្វើបាបចិត្តដែលកំពុងកើតអកុសលក្នុងខណៈនោះ

និងនៅធ្វើបាបតទៅដល់អ្នកដទៃជាច្រើននាក់ទៀត

តាមកម្លាំងរបស់អកុសលនោះ ៗ ។

១៤៧. យើងមានជីវិតនៅក្នុងលោកនេះ

មិនដឹងថាពេលណានឹងលាពីលោកនេះទៅឡើយ

អ្វីក៏មិនអាចជាប់ទៅជាមួយខ្លួនបានឡើយ

ទ្រព្យសម្បត្តិ ឬរាងកាយ ក៏មិនអាចទៅជាមួយបានឡើយ ។

ប៉ុន្តែ ការយល់ត្រូវ ឃើញត្រូវ

ដែលសន្សំសន្សឹមៗនូវសេចក្តីមិនប្រមាទ បន្តិចម្តងៗ ច្រើនឡើង ។

១៤៨. កុសលទាំងឡាយប្រព្រឹត្តទៅតាមកម្លាំងរបស់បញ្ញា

ចម្រើនកុសលភ្លាមៗ ដោយមិនចាំបាច់រវេរា

ព្រោះនរណានឹងដឹងថាខណៈតទៅកើតជាអ្វី

ជាអកុសលក៏បានដែរ ។

១៤៩. ការបំផ្លាញព្រះពុទ្ធសាសនា ឬការមិនប្រព្រឹត្តប្រតិបត្តិ

តាមព្រះធម្មវិន័យ ជាទោសដ៏ធ្ងន់ណាស់សម្រាប់បុគ្គលនោះ

និងសម្រាប់អ្នកដទៃ ៗ ផងដែរ ព្រោះធ្វើអោយអ្នកដទៃយល់ខុសទៅដែរ

ទាំងអស់ ។ ព្រោះដូច្នោះ ក្លាហានដែលនឹងនិយាយការពិតឱ្យអ្នកដទៃដឹងថា

អ្វីត្រូវ អ្វីខុស ឬទេ ? ព្រោះយ៉ាងណាៗ ក៏ត្រូវតែស្លាប់

ហើយនឹងខ្លាចអ្វី នៅពេលដែលពាក្យនោះជាប្រយោជន៍

កាន់តែនិយាយ កាន់តែជាប្រយោជន៍ ។

១៥០. ជាធម្មតារបស់អ្នកដែលបានសន្សំមកដែលនឹងដឹងថាអ្វីដែលមានប្រយោជន៍បំផុត

ក្នុងជីវិតនៅក្នុងសង្សារវដ្ត គឺ ការដែលយល់នូវការពិត

ប្រសិនបើអាចនឹងឱ្យនរណាយល់ការពិតបាន

ក៏ដូចដែលអ្នកនោះបានតបស្នងសងគុណរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

អ្វីដែលព្រះអង្គប្រព្រឹត្ត គេក៏ធ្វើតាម តៗ គ្នាទៅ

ដើម្បីប្រយោជន៍ដល់អ្នកដទៃ ។

លក្ខណៈ របស់វាចានោះ នៅមាន

ហេតុនោះ វាចានោះ ឈ្មោះថា មានលក្ខណៈ

អធិប្បាយថា បុគ្គលអ្នកដែលគួរជឿបាននោះ

រមែងជាអ្នកពោលនូវវាចាដ៏សមគួរ

ដែលអាចរក្សាទុកនៅក្នុងបេះដូងបាន ។

(*បបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ មូលបណ្ណាសក ចូឡហត្ថិបទោបមសូត្រ*)

ព្រះថេរៈ ពោលព្រះធម៌និងព្រះវិន័យ

ពាក្យពេជន៍របស់ព្រះថេរៈនោះ

រមែងអាចនឹងជារបស់សមគួររក្សាទុកក្នុងបេះដូង

ដូចសំពត់ដែនកាសី នោះ

ដែលបុគ្គលគួររក្សាទុកក្នុងប្រអប់គ្រឿងក្រអូប ដូច្នោះ(ឯង) ។

(*ព្រះអភិធម្មបិដក បុគ្គលបញ្ញត្តិ*)

## មូលនិធិសិក្សានិងផ្សព្វផ្សាយព្រះពុទ្ធសាសនា

**Dhamma study and support foundation**

174/1 Charoennakorn 78, Dao Khanong Subdistrict,

Thonburi District, Bangkok 10600

Phone: 0 2468 0239

Fax: 0 2877 9693

Website: www.dhammahome.com

Email: info@dhammahome.com